ការចេញផ្សាយលើកទី ២ ខែ ធ្នូ ២០១៨

មាតិកា

១. អំពីវគ្គបំប៉ន១របស់គម្រោង TIGER
២. រឿងនិទានតាមរយៈកម្មវិធី App
៣. ការចូលរួមរបស់អង្គការសង្គមស៊ីវិល
៤. ទំនាក់ទំនង

TIGER
លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការ បង្រៀន និង រៀន
TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

អំពីវគ្គបំប៉ន១របស់គម្រោង TIGER

បន្ទាប់ពីទទួលបានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឬា វគ្គបំប៉ន១សាកល្បងស្តីពី**ភាពជាអ្នកដឹកនាំសាលារៀន និងការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ** ត្រូវបានរៀបចំឡើងក្នុងចន្លោះខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ ២០១៨។ គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្ប និងជនបង្គោលយេនឌ័ររបស់ក្រសួងអប់រំ យុវជន និងកីឬា មន្ទីរអប់រំ យុវជន និងកីឬាខេត្ត មន្ទីរកិច្ចការនារីខេត្ត ការិយាល័យអប់រំ យុវជន និងកីឬាក្នុងខេត្តបាត់ដំបង និងបុគ្គលិករបស់អង្គការសង្គមស៊ីវិលទាំង៥ សរុបចំនួន៨៩នាក់ ស្រី៤២នាក់បានចូលរួមវគ្គបំប៉ននេះ។ សិក្ខាកាមដែលបានចូលរួមលើកឡើងថាវាជាវគ្គបំប៉នដែលមានភាពស៊ីជម្រៅ និងខ្លឹមសារច្បាស់លាស់។ អ្នកសម្របសម្រួលវគ្គបំប៉នបានបង្កលក្ខណៈឱ្យសិក្ខាកាមទាំងអស់ចូលរួមយ៉ាងសកម្មក្នុងគ្រប់សកម្មភាពបង្រៀន និងរៀន ទន្ទឹមនឹងនោះសិក្ខាកាមក៏បានចែករំលែកគំនិតនិងបទពិសោធន៍របស់ខ្លួនលើការរៀបចំសាលារៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ ដែលផ្តល់ជាធាតុចូលល្អៗក្នុងការកែលម្អឯកសារណែនាំនេះ។

សិក្ខាកាមធ្វើការជាដៃគូដើម្បីដកពិសោធន៍ពីផលប៉ះពាល់នៃផ្នត់គំនិតវិសមភាពយេនឌ័រនៅក្នុងការរស់នៅ និងសង្គម។

រឿងនិទានតាមរយៈកម្មវិធី App



កម្មវិធី App ដែលមានរឿងនិទានបែបអន្តរកម្ម គឺជាបណ្ណាល័យឌីជីថលមួយដែលមានរឿងនិទានជាច្រើនសម្រាប់គ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយ និងសហគមន៍។ រឿងនិទានទាំងនោះឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងអំពីសមភាព និងវិសមភាពយេនឌ័រ ឬផ្នត់គំនិតយេនឌ័រដែលកើតមានឡើងនៅតាមសហគមន៍។ គ្រប់សាច់រឿងនិទានទាំងអស់នៅក្នុងបណ្ណាល័យនេះគឺមានភាពរស់រវើក។ នៅពេលដែលរឿងនិទានបង្ហាញឡើង អ្នកអានអាចជ្រើសរើសប៊ូតុង (button) បញ្ជាដើម្បីសិក្សាពីតួអង្គ និងសាច់រឿង។ លទ្ធផលនៃសាច់រឿងនឹងបង្ហាញចេញមកអាស្រ័យតាមការជ្រើសរើសប៊ូតុងបញ្ជាណាមួយ។ រឿងនិទានទាំងនេះផ្តល់ជាមេរៀនបទពិសោធន៍ និងអប់រំដល់អ្នកអាន ឱ្យទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលចាំបាច់ នៅក្នុងសង្គមដែលមានការវិវឌ្ឍយ៉ាងឆាប់រហ័ស។

អ្នកនិពន្ធសរសេររឿងនិទាន ហើយដាក់ចូល (upload) ក្នុងបណ្ណាល័យឌីជីថល តាមរយៈគេហទំព័រ www.tigerkh.org ។ បណ្ណាល័យនេះអាចដាក់បានរឿងនិទានច្រើនដោយគ្មានកំណត់ចំនួន សម្រាប់អ្នកអានទាញយក (download) ទុកអានពេលក្រោម។

សូមអញ្ជើញលោកអ្នក ទាញយកកម្មវិធីនេះដាក់ក្នុងទូរស័ព្ទ ហើយសាកល្បងអានរឿងនិទាន។ លោកអ្នកអាចស្វែងរកកម្មវិធីនេះនៅក្នុង PlayStore ឬតាមរយៈតំណភ្ជាប់នេះ: www.bit.ly/tigermobile។

ការចូលរួមរបស់អង្គការសង្គមស៊ីវិល

គម្រោង TIGER បានជ្រើសរើសដៃគូសហការពីអង្គការសង្គមស៊ីវិលចំនួន៥ ដែលជាភាគីទីបីក្នុងការអនុវត្តគម្រោង។ អង្គការសង្គមស៊ីវិលទាំងនេះនឹងទទួលបានការអភិវឌ្ឍសមត្ថភាពរយៈពេល ២ ឆ្នាំស្តីពី**ភាពជាអ្នកដឹកនាំសាលារៀន និងការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។** គម្រោងនឹងផ្តល់ជំនួយថវិកាខ្នាតតូចដល់អង្គការនីមួយៗដើម្បីរៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពដល់សាលារៀនគោលដៅចំនួន២០បន្ថែមទៀត។ ក្រុមការងារគម្រោង TIGER នឹងផ្តល់ការណែនាំ និងជំនួយបច្ចេកទេសដល់អង្គការសង្គមស៊ីវិលទាំងនេះ ក្នុងប្រែក្លាយសាលារៀនគោលដៅរបស់ខ្លួនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ។ យើងមានសេចក្តីរីករាយក្នុងការណែនាំអង្គការសង្គមស៊ីវិលទាំង ៥ និងសូមស្វាគមន៍ពួកគាត់ចូលជាសមាជិករបស់គម្រោង TIGER ។

អង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍន៍

អង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍន៍បានបង្កើតកម្មវិធីអប់រំ និងបណ្តុះបណ្តាលដល់សមាជិកគ្រួសារទាំងអស់អំពីការអប់រំសហគមន៍ អាហារូបត្ថម្ភ ការដាំបន្លែ និងកីឬ។ ក្នុងនោះផងដែរ យើងក៏បានណែនាំឪពុកម្តាយអំពីសារៈសំខាន់នៃការបញ្ជូនកូនរបស់ពួកគាត់ទៅសាលារៀន និងការកាត់បន្ថយពលកម្មកុមារ។ កុមារអាចរៀនពីបំណិនជីវិត និងអភិវឌ្ឍផ្នែកបញ្ញាស្មារតី និងរាងកាយតាមរយៈកម្មវិធីកីឬ។

អង្គការខ្មែរដើម្បីការអប់រំ KHEN

អង្គការខ្មែរដើម្បីការអប់រំ ធ្វើសកម្មភាពក្នុងខេត្តបាត់ដំបងដើម្បីពង្រឹងគុណភាពអប់រំ។ អង្គការខ្មែរដើម្បីការអប់រំបានកសាង និងជួសជុលសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា អប់រំ និងធ្វើការតស៊ូមតិអំពីសិទ្ធិកុមារ ជាពិសេសកុមារពិការ។ KHEN ក៏បានធ្វើយុទ្ធនាការប្រមូលសិស្សចុះឈ្មោះចូលរៀន និងធានាឱ្យមានការមករៀនទៀងទាត់របស់កុមារដោយមានការជួយជ្រោមជ្រែងពីឪពុកម្តាយ រៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពដល់គ្រូបង្រៀន ផ្តល់ជំនួយបន្ទាន់ដល់កុមារក្នុងស្ថានភាពអាសន្ន និងសម្របសម្រួលកិច្ចប្រជុំរវាងសាលារៀន ដៃគូ និងអជ្ញាធរមូលដ្ឋាន។

អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ

បេសកកម្មរបស់អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ គឺផ្តល់ឱ្យក្មេងស្រីនិងស្ត្រីនៅតាមតំបន់ជនបទនៅភាគពាយ័ព្យនៃប្រទេសកម្ពុជានូវជំនាញ និងការគាំទ្រចាំបាច់ដើម្បីកសាងសហគមន៍របស់ពួកគាត់ឱ្យមានសុខុមាលភាពល្អ សន្តិភាព និងបរិយាប័ន្ន។ គម្រោងធ្វើការផ្តោតលើក្មេងស្រី និងស្ត្រី ប៉ុន្តែគម្រោងក៏បានផ្តល់ផលប្រយោជន៍ដល់ក្មេងប្រុស និងបុរសផងដែរ។ អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទបានផ្តល់នូវការកសាងសមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនស្តីពីវិធីសាស្ត្របង្រៀន ការផលិតសម្ភារៈឧបទេស ការរៀបចំកិច្ចប្រជុំជាមួយមាតាបិតា ការបង្កើតក្លឹបអ្នកអភិរក្សបរិស្ថាន ទឹកស្អាត និងអនាម័យ។ អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទក៏បានផ្តល់សម្ភារៈបង្រៀន និងរៀន បង្កើតក្លឹបកីឬ ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងគាំទ្របណ្ណាល័យសាលារៀនជាដើម។

អង្គការផ្ទះទឹកដូងកម្ពុជា

អង្គការផ្ទះទឹកដូងកម្ពុជាផ្តោតយកចិត្តទុកដាក់លើសហគមន៍ និងផ្តល់អំណាចដល់កុមារ និងមនុស្សពេញវ័យតាមរយៈការអប់រំ ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់ជីវភាពរស់នៅរបស់សហគមន៍ និងសហគ្រិនភាព។ អង្គការផ្ទះទឹកដូង បង្កើតមជ្ឈមណ្ឌលសហគមន៍កាត់ដេរ ភោជនីយដ្ឋាន ផ្ទះសម្រាប់លម្ហែ និងហាងលក់វត្ថុអនុស្សាវរីយ ផ្តល់ការគាំទ្រដល់កសិដ្ឋាន និងទីផ្សាររបស់សហគមន៍ កសាងសាលារៀន និងបណ្តុះបណ្តាលគ្រូបង្រៀនភាសាអង់គ្លេស ICT អាហារូបត្ថម្ភ និងការបង្រៀនសិស្សរៀនយឺត។

អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍

អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍បានលើកកម្ពស់សិទ្ធិកុមារ និងសាលារៀនកុមារមេត្រីដោយផ្តោតលើសមាសភាគទាំងប្រាំមួយគឺ *(១)ការអប់រំប្រកបដោយបរិយាប័ន្ន (២)ការសិក្សាប្រកបដោយប្រសិទ្ធភាព (៣)សុខភាព សុវត្ថិភាព និងការការពារកុមារ (៤)ការឆ្លើយតបទៅនឹងយេនឌ័រ (៥)ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ក្នុងដំណើរការសាលារៀនតាមមូលដ្ឋាន (៦)ប្រព័ន្ធអប់រំជាតិផ្តល់ការជួយគាំទ្រកម្មវិធីសាលាកុមារមេត្រី និងលើកទឹកចិត្តដល់សាលារៀនឱ្យទៅជាសាលាកុមារមេត្រី។* តាមរយៈការផ្តល់ការអប់រំដោយឥតគិតថ្លៃដល់កុមារក្រីក្រនិងក្រុមគ្រួសារ និងការវិនិយោគលើការអភិវឌ្ឍសហគមន៍ គោលដៅរបស់ CTOD គឺជួយដោះស្រាយបញ្ហាប្រឈមរបស់គ្រួសារដើម្បីឱ្យមានជីវភាពល្អប្រសើរជាងមុន។

អាសយដ្ឋាន៖ ផ្ទះលេខ B-53, ភូមិកម្មករ, សង្កាត់ស្វាយប៉ោ, ក្រុង-ខេត្តបាត់ដំបង, ប្រទេសកម្ពុជា។
គេហទំព័រ៖ www.cambodia.vvob.be/tiger
ស្វែងរកពួកយើងតាមរយៈហ្វេកបុក៖ @vvobcambodia, @kapeaction, @genderissue, @pkocambodia.org

ព្រឹត្តិប័ត្រព័ត៌មាននេះ ផលិតដោយមានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ខ្លឹមសារដែលមានក្នុងព្រឹត្តិប័ត្រនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ អង្គការ VVOB, GADC, PKO និង KAPE ហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។ រដ្ឋាភិបាលបែលហ្ស៊ិកមិនអាចទទួលខុសត្រូវចំពោះខ្លឹមសាររបស់ព្រឹត្តិប័ត្រព័ត៌មាននេះដែរ។